


# ការស្នើសុំលិខិតអនុញ្ញាតលើវិស័យសំណង់ នៅការិយាល័យច្រកចេញចូលតែមួយ

## I. សារៈសំខាន់នៃការសុំលិខិតអនុញ្ញាតលើការសាងសង់

- បញ្ជាក់ពីភាពត្រឹមត្រូវតាមច្បាប់នៃសំណង់
- គោរពតាមច្បាប់រដ្ឋ
- និងផលប្រយោជន៍ផ្សេងៗជាច្រើនទៀត។

## II. ប្រភេទសំណង់ក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់ ឬជួសជុល

- ភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ ដែលមានផ្ទៃក្រឡាកម្រាលសរុប មិនលើស ៥០០ម៉ែត្រការេ និងមានកម្ពស់មិនលើសពី ២ជាន់ គឺជាន់ផ្ទាល់ដី និងជាន់ទី១។
- របងដែលមានកំពស់មិនលើស ២ម៉ែត្រ គិតពីកម្រិតកម្ពស់ដីនៅជើងរបង។

## III. បែបបទនៃការស្នើសុំសាងសង់

- អតិថិជនត្រូវមកទំនាក់ទំនងមន្ត្រីផ្នែកជួរមុខនៃការិយាល័យច្រកចេញចូលតែមួយ ដើម្បីសាកសួរព័ត៌មាន និងស្នើសំណុំឯកសារនៃពាក្យសុំ។
- អតិថិជនត្រូវបំពេញទម្រង់បែបបទនៃពាក្យសុំដោយខ្លួនឯង។ សម្រាប់ប្រជាពលរដ្ឋ ដែលមិនចេះអក្សរ និងមិនអាចបំពេញលើទម្រង់បែបបទដោយខ្លួនឯងបាន មន្ត្រីផ្នែកជួរមុខអាចជួយបំពេញជំនួសដោយសេចក្តីពេញចិត្ត។
- បន្ទាប់ពីមន្ត្រីផ្នែកជួរមុខដែលបានទទួល និងពិនិត្យទម្រង់បែបបទពាក្យស្នើសុំ និងឯកសារភ្ជាប់ដែលមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវរួចហើយ នឹងចេញបង្កាន់ដៃទទួលពាក្យ ដោយមានកំណត់កាលបរិច្ឆេទទទួលលិខិតអនុញ្ញាតនោះ។

- សំណុំឯកសារ និងទម្រង់បែបបទនៃពាក្យសុំមានដូចជា:

☑ ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ឬជួសជុល ចំនួន ០១ច្បាប់ ដោយភ្ជាប់មកជាមួយនូវ:

- អត្តសញ្ញាណប័ណ្ណ ឬប័ណ្ណគ្រួសារ (ថតចំលង) ០១ ច្បាប់
- ប្លង់សម្គាល់កម្មសិទ្ធិដី និងប្លង់ទីតាំងដី ០១ ច្បាប់
- ប្លង់ស្ថាបត្យកម្ម ០៤ ច្បាប
- ប្លង់គ្រឿងបង្គុំសំណង់ ០៤ ច្បាប់
- កិច្ចសន្យាអ្នកជាប់ព្រំ ០១ ច្បាប់

☑ សំណុំឯកសារពាក់ព័ន្ធមួយចំនួនទៀត ដូចជា ពាក្យសុំលិខិតអនុញ្ញាតបើក និងបិទការដ្ឋានជាដើម ។ល។

(បញ្ជាក់: ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ឬ ជួសជុលនេះ ត្រូវអនុវត្តតាមមាត្រា៩ ជំពូកទី៣ និងមាត្រា២២ ជំពូកទី៥ នៃអនុក្រឹតលេខ៨៦ អនក្រ បន ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងពាក្យសុំលិខិតអនុញ្ញាតបើក ឬបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ត្រូវអនុវត្តតាមប្រការ៣ ប្រការ១១ និងប្រការ១២ នៃប្រកាស លេខ៣២ ប្រក សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់)។

- ការត្រួតពិនិត្យសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតរបស់សាលាក្រុងមានរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការ។ រយៈពេលត្រួតពិនិត្យរាល់សំណុំឯកសារនៃពាក្យសុំ ត្រូវគិតចាប់ពីថ្ងៃដែលចេញបង្កាន់ដៃទទួលសំណុំឯកសារនៃពាក្យសុំ។



☑ ប្លង់ដី (ប័ណ្ណកម្មសិទ្ធិ)



☑ ពាក្យស្នើសុំសាងសង់




☑ សៀវភៅគ្រួសារ



☑ ប្លង់ស្ថាបត្យកម្ម (ប្លង់សំណង់)




☑ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

## IV. ការបង់ថ្លៃសេវា

- ការបង់ថ្លៃសេវាគឺជាដំណាក់ចុងក្រោយនៃសំណុំបែបបទស្នើសុំ។
- អតិថិជនត្រូវបង់ថ្លៃសេវាកម្មដោយខ្លួនឯងផ្ទាល់នៅបញ្ជរទទួលប្រាក់។
- រាល់ព័ត៌មានអំពីតម្លៃសេវាកម្មទាំងអស់ ត្រូវបានដាក់បង្ហាញក្នុងខិត្តប័ណ្ណផ្សព្វផ្សាយជាសាធារណៈ និងបិទនៅតាមជញ្ជាំងការិយាល័យច្រកចេញចូលតែមួយ។

## V. រយៈពេល

១៥ថ្ងៃនៃថ្ងៃធ្វើការ (មានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ)។

## VI. តារាងតម្លៃសេវាកម្ម

**តារាងតម្លៃសេវាកម្មលើវិស័យសំណង់**

| សេវាកម្ម (លំនៅឋាន) | តម្លៃសេវាកម្ម | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ពាក្យសុំ | តែមប្រ៏ | បង្កាន់ដៃ | ផ្ទៃក្រឡាកម្រាលសំណង់ | | | | |
| | | | | ≤១០០ម² | ≤២០០ម² | ≤៣០០ម² | ≤៤០០ម² | ≤៥០០ម² |
| **លិខិតអនុញ្ញាតសាងសង់ ជាន់ផ្ទាល់ដី និងជាន់ទី១** | | | | | | | | |
| ១. ភូមិគ្រឹះ | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ១២០.០០០ ៛ | ១៤០.០០០ ៛ | ១៦០.០០០ ៛ | ១៨០.០០០ ៛ | ២០០.០០០ ៛ |
| ២. ផ្ទះល្វែង | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ៨០.០០០ ៛ | ១០០.០០០ ៛ | ១២០.០០០ ៛ | ១៤០.០០០ ៛ | ១៦០.០០០ ៛ |
| ៣. ផ្ទះក្រោមឈើលើ | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ៤០.០០០ ៛ | ៦០.០០០ ៛ | ៨០.០០០ ៛ | ១០០.០០០ ៛ | ១២០.០០០ ៛ |
| **លិខិតអនុញ្ញាតសាងសង់ ពង្រីកបន្ថែម រុះរើ ជួសជុល** | | | | | | | | |
| ១. ភូមិគ្រឹះ | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ៨០.០០០ ៛ | ១០០.០០០ ៛ | ១២០.០០០ ៛ | ១៤០.០០០ ៛ | ១៦០.០០០ ៛ |
| ២. ផ្ទះល្វែង | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ៤០.០០០ ៛ | ៦០.០០០ ៛ | ៨០.០០០ ៛ | ១០០.០០០ ៛ | ១២០.០០០ ៛ |
| ៣. ផ្ទះក្រោមឈើលើ | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ២០.០០០ ៛ | ៤០.០០០ ៛ | ៦០.០០០ ៛ | ៨០.០០០ ៛ | ១០០.០០០ ៛ |
| **លិខិតអនុញ្ញាតបើកការដ្ឋាន** | | | | | | | | |
| ១. ភូមិគ្រឹះ | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ២០.០០០ ៛ | ២៥.០០០ ៛ | ៣០.០០០ ៛ | ៣៥.០០០ ៛ | ៤០.០០០ ៛ |
| ២. ផ្ទះល្វែង | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ១០.០០០ ៛ | ១៥.០០០ ៛ | ២០.០០០ ៛ | ២៥.០០០ ៛ | ៣០.០០០ ៛ |
| ៣. ផ្ទះក្រោមឈើលើ | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ៥.០០០ ៛ | ១០.០០០ ៛ | ១៥.០០០ ៛ | ២០.០០០ ៛ | ២៥.០០០ ៛ |
| **លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ** | | | | | | | | |
| ១. ភូមិគ្រឹះ | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ២៥.០០០ ៛ | ៣០.០០០ ៛ | ៣៥.០០០ ៛ | ៤០.០០០ ៛ | ៤៥.០០០ ៛ |
| ២. ផ្ទះល្វែង | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ១៥.០០០ ៛ | ២០.០០០ ៛ | ២៥.០០០ ៛ | ៣០.០០០ ៛ | ៣៥.០០០ ៛ |
| ៣. ផ្ទះក្រោមឈើលើ | ២.០០០ ៛ | ២.០០០ ៛ | ៥០០ ៛ | ១០.០០០ ៛ | ១៥.០០០ ៛ | ២០.០០០ ៛ | ២៥.០០០ ៛ | ៣០.០០០ ៛ |

| សេវាកម្ម ជួសជុល និងសាងសង់របង | ពាក្យសុំ+តែមប្រ៏+បង្កាន់ដៃ | ប្រវែងបណ្តោយរបង | | | | | |
|---|---|---|---|---|---|---|---|
| | | ≤២០ម | ≤២០០ម | ≤៥០០ម | ≤១០០០ម | ≤៥០០០ម | >៥០០០ម |
| លិខិតអនុញ្ញាត | ២.០០០ ៛+២.០០០ ៛+៥០០ ៛ | ២០.០០០ ៛ | ៤០.០០០ ៛ | ៦០.០០០ ៛ | ៨០.០០០ ៛ | ១០០.០០០ ៛ | ១៥០.០០០ ៛ |
| លិខិតបើកការដ្ឋាន | ២.០០០ ៛+២.០០០ ៛+៥០០ ៛ | ៥.០០០ ៛ | ៨.០០០ ៛ | ១១.០០០ ៛ | ១៤.០០០ ៛ | ១៧.០០០ ៛ | ៣០.០០០ ៛ |
| លិខិតបិទការដ្ឋាន | ២.០០០ ៛+២.០០០ ៛+៥០០ ៛ | ១០.០០០ ៛ | ១៥.០០០ ៛ | ២០.០០០ ៛ | ២៥.០០០ ៛ | ៣០.០០០ ៛ | ៦០.០០០ ៛ |

លិខិតអនុញ្ញាតសាងសង់ សាងសង់ពង្រីកបន្ថែម ជួសជុល រុះរើ មានសុពលភាពរយៈពេល១ឆ្នាំ និងអាចពន្យារពេលបានម្តង



ផលិតដោយ : API BUILDING CAPACITY FOR CHANGE

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

សហការជាមួយ :

ឧបត្ថម្ភដោយ : សមាសភាគស្ថាប័នមិនមែនរដ្ឋនៃគម្រោង DFGG